

អេ ជេ អេហ្វ
ACLEDA-JARDINES FOUNDATION

# ឯកសារដេញថ្លៃសម្រាប់គម្រោង៖

សាលាបឋមសិក្សាភ្នាក់រលឹក (ព្រះវិហារ)

សាលាបឋមសិក្សាកោះទន្សាយសែនជ័យ (ស្ទឹងត្រែង)

ឆ្នាំសម្រាប់២០២៧

# មាតិកា


**លិខិតអញ្ជើញចូលរួមដេញថ្លៃ ........ 1**

ព័ត៌មានទូទៅ៖ ........ 1

ព័ត៌មានសំខាន់៖ ........ 1

ឯកសារសំខាន់ៗភ្ជាប់មកជាមួយឯកសារដេញថ្លៃ ៖ ........ 2

ព័ត៌មានទំនាក់ទំនង៖ ........ 2

កំណត់សម្គាល់៖ ........ 2

សំណើសុំចូលរួមដេញថ្លៃ ........ 4

សេចក្ដីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ ........ 6

**ការណែនាំសម្រាប់អ្នកចូលរួមដេញថ្លៃ ........ 7**

របៀបទទួលឯកសារដេញថ្លៃ៖ ........ 7

ទំហំការងារដេញថ្លៃ ........ 7

លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ៖ ........ 8

ការបំពេញតម្លៃ ........ 8

ឯកសារដេញថ្លៃសំខាន់ៗ ៖ ........ 9

ការរៀបចំឯកសារដេញថ្លៃ ៖ ........ 9

ដំណើរការបើក និងការវាយតម្លៃឯកសារដេញថ្លៃ ........ 10

**លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ ........ 10**

ព័ត៌មានទូទៅ៖ ........ 10

វិញ្ញាបនប័ត្រដែលត្រូវភ្ជាប់មកជាមួយ ........ 11

ព័ត៌មានហិរញ្ញវត្ថុ ........ 11

បទពិសោធន៍របស់ក្រុមហ៊ុន ........ 11

គ្រឿងចក្ររបស់ក្រុមហ៊ុន ........ 12

រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ឬឯកត្តបុគ្គល ........ 12

តារាងពេលវេលា ..................... 13

**លក្ខខណ្ឌទូទៅនៃកិច្ចសន្យា ..................... 14**

រយៈពេល ..................... 14

ការបង់ប្រាក់ ..................... 14

ការធានា និងការទទួលខុសត្រូវ ..................... 14

លក្ខខណ្ឌផ្សេងៗ ..................... 15

ការបញ្ចប់កិច្ចសន្យា ..................... 16

ការអនុវត្តកិច្ចសន្យា ..................... 17

**ឧបសម្ព័ន្ធ ០១ ..................... 19**

បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់ ..................... 19

បទដ្ឋានបច្ចេកទេស ..................... 19

ការរៀបចំការដ្ឋាន ..................... 19

ការងារបេតុង៖ ..................... 19

ជើងតាង៖ ..................... 19

សរសរតឿ៖ ..................... 19

ជញ្ជាំងទប់ដី៖ ..................... 19

ការបង្ហាប់ដីក្រោមកម្រាលជាន់៖ ..................... 20

ការងារផ្ទឹមក្រោម៖ ..................... 20

ការងារបង្ហាប់ថ្មក្រោមកម្រាលជាន់៖ ..................... 20

ជម្រាលជនពិការ ជណ្តើរ និងកន្លែងដាំផ្កា៖ ..................... 20

ការងារសរសរ៖ ..................... 20

ការងាររៀបឥដ្ឋជញ្ជាំង៖ ..................... 20

ឡាំងតូ៖ ..................... 21

ការងារផ្ទឹម និងសរសរសម្រាប់ដំបូល៖ ..................... 21

បង្កង់ និងដែរណែង៖ ......21
ក្បឿង ព្រំ និងជហ្វា៖ ......21
ការងារឈើ ឬដែក៖ ......21
កម្រាលជាន់៖ ......22
ការងារលាបថ្នាំ៖ ......22
បទដ្ឋានក្នុងការប្រើសម្ភារសម្រាប់បេតុង និងបាយអរ ......22
បញ្ជីលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ ......24
**ឧបសម្ព័ន ០២ ......29**
**គំនូសប្លង់ (សូមមើលគំនូសប្លង់លម្អិតភ្ជាប់មកជាមួយ) ......29**
**ឧបសម្ព័ន ០៣ ......29**
**បញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម (BoQ) & បញ្ជីទូទាត់ចំណាយតាមដំណាក់កាល ......29**
**(សូមមើលបញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម លម្អិតភ្ជាប់មកជាមួយ) ......29**
**ឧបសម្ព័ន ០៤ ......29**

## លិខិតអញ្ជើញចូលរួមដេញថ្លៃ

## ព័ត៌មានទូទៅ៖

អេស៊ីលីដា-ចារឌីន ជាអង្គការមូលនិធិមួយ ដែលទទួលជំនួយពីធនាគារ អេស៊ីលីដា ភីអិលស៊ី ក្រុមហ៊ុនចារឌីន និង ក្រុមហ៊ុនធានារ៉ាប់រងហ្វតេ ព្រមទាំងសាធារណជនជាច្រើន ជាពិសេសបុគ្គលិកគ្រប់ជាន់ថ្នាក់ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីជួយកុមារកម្ពុជា នៅតាមទីជនបទដាច់ស្រយាល ឲ្យមានឱកាសទទួលបានការអប់រំស្មើៗគ្នាតាមរយៈការសាងសង់ជូន នូវអគារសិក្សាតាមមូលដ្ឋាន ។

អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ សូមគោរពអញ្ជើញអ្នកម៉ៅការទាំងអស់ដែលមានបំណង ដើម្បីចូលរួមដេញថ្លៃសាងសង់អគារសិក្សា**មួយ និង/ឬពីរ**ខ្នង ដែលមួយខ្នងមាន **០៥បន្ទប់**ដែលកំណត់ រយៈពេលសាងសង់ **ចំនួន ២១០ ថ្ងៃប្រតិទិន** ដោយរាប់បញ្ចូលទាំងថ្ងៃឈប់សម្រាក និងបុណ្យជាតិ-អន្តរជាតិផ្សេងៗ ចាប់ពីពេលផ្សាយដំណឹងនេះទៅ ដែលមានឈ្មោះសាលា និងស្ថិតក្នុងខេត្តដូចខាងក្រោម៖

| ល.រ | ឈ្មោះសាលា | ទំហំសាលា | អាសយដ្ឋាន |
|---|---|---|---|
| ១ | សាលាបឋមសិក្សាត្នោតភ្លាក់រលីក | ១ខ្នង ៥បន្ទប់ និងជួសជុលបន្ទប់ទឹក១ | ខេត្តព្រះវិហារ |
| ២ | សាលាបឋមសិក្សាកោះទន្សាយ សែនជ័យ | ១ខ្នង ៥បន្ទប់ | ខេត្តស្ទឹងត្រែង |

## ព័ត៌មានសំខាន់៖

អង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ សូមអញ្ជើញ **ក្រុមហ៊ុន ឬឯកត្តបុគ្គល** ទាំងអស់ដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ចូលរួមដេញថ្លៃដោយបំពេញនូវឯកសារដេញថ្លៃតាមលក្ខណដែលបានកំណត់ រួចផ្ញើមក **លោក មាស សុជាតិ លេខទូរសព្ទ 015 500 728, អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា** ត្រឹមម៉ោង **១៦:០០នាទីល្ងាច ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៦** ដោយសរសេរឈ្មោះ អាសយដ្ឋាន គម្រោងសាងសង់ឲ្យបានច្បាស់លាស់នៅស្រោមសំបុត្រដោយប្រថាប់ត្រាក្រុមហ៊ុនសម្រាប់ក្រុមហ៊ុន និងចុះហត្ថលេខាសម្រាប់ឯកត្តបុគ្គល នៅលើមាត់ស្រោមសំបុត្រដែលបិទរួច ។ អង្គការមិនទទួលយកឯកសារដេញថ្លៃណាដែលហួសពេលកំណត់ ដោយឥតលក្ខខណ្ឌឡើយ ។ ឯកសារដេញថ្លៃដែលបានផ្ញើមកហើយ មិនអាចប្រគល់ត្រឡប់វិញទេ ។ តម្រូវការចាំបាច់ដែលក្រុមហ៊ុន ឬឯកត្តបុគ្គល ត្រូវផ្ញើរួមមានឯកសារច្បាប់ដើម ***(១) សេចក្តីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ (២) (ឧបសម្ព័ន្ធ(៣) បញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម (BoQ) និងបញ្ជីទូទាត់ចំណាយតាមដំណាក់កាល និង (៣) ឧបសម្ព័ន្ធ(៤) ទម្រង់ប្រកាសលក្ខខណ្ឌនៃការដេញថ្លៃ) ច្បាប់ដើម*** ។ **ចំពោះឯកសារផ្សេងទៀត តម្រូវតាមក្រោយ មុនពេលចុះកិច្ចសន្យា** ឬតាមតម្រូវផ្ទាល់ ពេលអង្គការមានតម្រូវការ ។ អ្នកចូលរួមដេញថ្លៃគម្រោងសាងសង់របស់អង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំទាំងអស់ ត្រូវប្រាកដថាខ្លួនបានចុះសិក្សាគ្រប់ទីតាំងទាំងអស់មុននឹងដាក់

ពាក្យដេញថ្លៃ ។ ការចូលរួមដេញថ្លៃគឺដោយការប្រកួតប្រជែង គ្មានឃុបឃិត គ្មានស៊ុមគ្រលុំគ្នា មិនពាក់ព័ន្ធនឹងការក្លែងបន្លំ ឬអំពើពុករលួយឡើយ ។

## ឯកសារសំខាន់ៗភ្ជាប់មកជាមួយឯកសារដេញថ្លៃ ៖

ឯកសារសំខាន់ៗដែលភ្ជាប់មកជាមួយឯកសារដេញថ្លៃរួមមាន ៖

1. សំណើសុំចូលរួមដេញថ្លៃ
2. សេចក្ដីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ
3. ការណែនាំសម្រាប់អ្នកចូលរួមដេញថ្លៃ
4. លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ
5. លក្ខខណ្ឌទូទៅនៃកិច្ចសន្យា
6. ឧបសម្ព័ន្ធ(១) បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់
7. ឧបសម្ព័ន្ធ(២) គំនូសប្លង់
8. ឧបសម្ព័ន្ធ(៣) បញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម (BoQ) និងបញ្ជីទូទាត់ចំណាយតាមដំណាក់កាល
9. ឧបសម្ព័ន្ធ(៤) ទម្រង់ប្រកាសលក្ខខណ្ឌនៃការដេញថ្លៃ

## ព័ត៌មានទំនាក់ទំនង៖

ខាងក្រោមជាអាសយដ្ឋាន ដែលអ្នកដេញថ្លៃទាំងអស់អាចទំនាក់ទំនងមកដើម្បីសាកសួរព័ត៌មាន, ដាក់សំណួរ និងដាក់ឯកសារដេញថ្លៃជាដើម នៅអគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ឬ www.ajf.org.kh ឬព័ត៌មានទំនាក់ទំនងមក ៖

- លោក មាស សុជាតិ Mr. Meas Socheat ប្រធានគ្រប់គ្រងការដ្ឋាន mail: Socheatmeas007@gmail.com, phone: 015 500 728
- លោក ជា សុបិន Mr. Chea Sobin ប្រធានគ្រប់គ្រងគម្រោង mail: chea.sobin@acledabank.com.kh, chea.sobin@gmail.com, or telegram +855(0) 15 800 854
- លោកស្រី ពៅ ទិត្យមិថុនា Ms. Peuo Titmithona ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង mail: mithona@acledabank.com.kh,phone: +855(0) 15 900 565

## កំណត់សម្គាល់៖

- ករណីគណៈកម្មការគម្រោងវាយតម្លៃទៅឃើញថា អ្នកចូលរួមដេញថ្លៃទាំងអស់ អាចទទួលយក០១ **ឬ០២**ខ្នងដែលមួយខ្នងមាន **០៥បន្ទប់** អ្នកចូលរួមដេញថ្លៃទាំងអស់ត្រូវទទួលយកដោយឥតលក្ខខណ្ឌ ។

- ករណីអ្នកចូលដេញថ្លៃបានទទួលជោគជ័យ និងចុះកិច្ចសន្យាជាមួយអង្គការរួចរាល់ហើយ តែបោះបង់ ឬបដិសេធ ឬមិនព្រមចូលសាងសង់ អ្នកចូលរួមដេញថ្លៃត្រូវសងជំងឺចិត្តដល់អង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ចំនួន ១០ % នៃតម្លៃសរុបក្នុងកិច្ចសន្យា ដើម្បីឲ្យអង្គការយកមករៀបចំដេញថ្លៃម្តងទៀត ឬអង្គការមិនអនុញ្ញាតឲ្យចូលរួមដេញថ្លៃជាមួយអង្គការលើកក្រោយទៀតទេ ឬអង្គការអាចពិចារណាតាមហេតុការណ៍ជាក់ស្តែង ។

អេស៊ីលីដា-ចារឌីន រង់ចាំទទួលឯកសារដេញថ្លៃ ពីអ្នកចូលរួមដេញថ្លៃទាំងអស់ ។ ជាថ្មីម្តងទៀតសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទុកជាមុនសម្រាប់ការចូលរួមដេញថ្លៃជាមួយយើងខ្ញុំ។

## សំណើសុំចូលរួមដេញថ្លៃ

សូមគោរពជូន

លោកប្រធានអង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ

កម្មវត្ថុ : សំណើសុំចូលរួមដេញថ្លៃសម្រាប់ការងារសាងសង់អគារសិក្សា**០១ និង/ឬ០២ខ្នង ០១ខ្នងមាន០៥បន្ទប់នៅសាលាបឋមសិក្សាភ្នាក់រលឹក និង/ឬនៅសាលាបឋមសិក្សាកោះទន្សាយសែនជ័យ។**

យោង : លិខិតអញ្ជើញចូលរួមដេញថ្លៃរបស់អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ ការអប់រំចុះថ្ងៃទី ............... ខែ.............ឆ្នាំ ..................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូម លោកប្រធានអង្គការ មេត្តាអនុញ្ញាតឲ្យខ្ញុំ ចូលរួមដេញថ្លៃសម្រាប់**ការងារសាងសង់អគារសិក្សាភ្នាក់រលឹក (ខេត្តព្រះវិហារ)** ០១ខ្នង ០៥បន្ទប់ និងជួសជុលបន្ទប់ទឹក២ តម្លៃសរុប ...................... ចំនួនអក្សរ ........................................................................................................................ និង/ឬសម្រាប់ **ការងារសាងសង់អគារសិក្សាកោះទន្សាយសែនជ័យ (ខេត្តស្ទឹងត្រែង)** ០១ខ្នង ០៥បន្ទប់ និងជួសជុលបន្ទប់ទឹក០២ តម្លៃសរុប ...................... ចំនួនអក្សរ .......................................................................................................................... ជាតម្លៃបញ្ចប់មួយគម្រោង ដែលបានមកពីការត្រួតពិនិត្យការដ្ឋានផ្ទាល់ លក្ខខណ្ឌនៃកិច្ចសន្យា បទដ្ឋានបច្ចេកទេស គំនូសប្លង់ បញ្ជីប៉ាន់ស្មានតម្លៃ និងឯកសារផ្សេងៗក្នុងការដេញថ្លៃយ៉ាងច្បាស់លាស់ ។

អាស្រ័យហេតុនេះ សូម លោកប្រធាន មេត្តាពិនិត្យ និងអនុញ្ញាតដោយក្តីអនុគ្រោះ ។

សូមលោកប្រធាន មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ថ្ងៃ......... ខែ............ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

.................... ថ្ងៃទី........ ខែ......... ឆ្នាំ២០២៦

ហត្ថលេខា ត្រា ឬស្នាមេដៃ និងឈ្មោះ

តួនាទី៖..................

## សេចក្តីប្រកាសក្រមសីលធមិវិជ្ជាជីវៈ

សេចក្តីប្រកាស
ស្តីពី
ក្រមសីលធមិវិជ្ជាជីវៈរបស់អ្នកចូលរួមប្រកួតប្រជែងដេញថ្លៃ
សាលាបឋមសិក្សា...................................................
សាលាបឋមសិក្សា...................................................

យើងខ្ញុំជាប្រធាន និយោជិត សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូរបស់យើងខ្ញុំ ឬញាតិសន្តាន សូមធ្វើការអះអាង នៅក្នុងការរៀបចំសំណើដេញថ្លៃរបស់យើងខ្ញុំថា ៖

១- មិនមានទំនាក់ទំនងណាមួយ ដែលអាចចាត់ទុកបានថាជាទំនាស់ផលប្រយោជន៍ ដូចមានចែងក្នុងឯកសារដេញថ្លៃ ។

២- ប្រសិនបើយើងខ្ញុំដឹងអំពីលទ្ធភាពដែលអាចកើតមាននូវទំនាស់នេះ យើងខ្ញុំត្រូវរាយការណ៍ជាបន្ទាន់ទៅស្ថាប័ន ឬសមត្ថកិច្ចអនុវត្តលទ្ធកម្ម ។

៣- មិនមានប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ផ្សំគំនិត ឬបង្ខិតបង្ខំ ទាក់ទិននឹងការដាក់សំណើដេញថ្លៃ របស់យើងខ្ញុំ ។

៤- យើងខ្ញុំយល់ច្បាស់អំពីកាតព្វកិច្ចរបស់យើងខ្ញុំ ក្នុងការអនុញ្ញាតឲ្យអង្គការ ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមទាំងអស់ ទាក់ទិននឹងការរៀបចំការដាក់ដេញថ្លៃរបស់យើងខ្ញុំ និងកិច្ចសន្យាណាមួយជាលទ្ធផលនៃការដាក់ដេញថ្លៃនេះ ដោយមិនគិតថា យើងខ្ញុំទទួលបានការសម្រេចប្រគល់កិច្ចសន្យា ឬអត់នោះទេ ។

៥- ពុំមានការទូទាត់ណាមួយទាក់ទិននឹងដំណើរការលទ្ធកម្មនេះ ត្រូវបានធ្វើឡើងដោយយើងខ្ញុំ សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ដៃគូរបស់យើងខ្ញុំ ឬញាតិសន្តានរបស់ពួកគេ ទៅឲ្យភ្នាក់ងារ ទីប្រឹក្សា និយោជិតឬញាតិសន្តានរបស់ពួកគេដែលចូលរួមក្នុងដំណើរការលទ្ធកម្មនេះជំនួសមុខឱ្យស្ថាប័ន អនុវត្តលទ្ធកម្ម នោះទេ ។

ថ្ងៃ......... ខែ...........ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

.................... ថ្ងៃទី........ ខែ......... ឆ្នាំ២០២៦

ហត្ថលេខា ត្រា ឬស្នាមេដៃ និងឈ្មោះ

តួនាទី៖...................

## ការណែនាំសម្រាប់អ្នកចូលរួមដេញថ្លៃ

អ្នកចូលរួមដេញថ្លៃទាំងអស់ត្រូវគោរព និងអនុវត្តតាមលក្ខខណ្ឌ នៃលក្ខខណ្ឌដេញថ្លៃដូចខាងក្រោម៖

## របៀបទទួលឯកសារដេញថ្លៃ៖

ក្រុមហ៊ុន ឬឯកត្តបុគ្គល ទាំងអស់ដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចចូលរួមដេញថ្លៃ និងទទួលយកឯកសារដេញថ្លៃគម្រោងសាងសង់សាលាបបមសិក្សារបស់អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំបានដោយឥតគិតថ្លៃជាផ្នែកទន់ (PDF រួមទាំង BOQ excel version) តាមរយៈតំណភ្ជាប់នៅក្នុង ការផ្សព្វផ្សាយផ្សេងៗដូចជា៖ Website, Facebook, Telegram, ~~Link In~~ របស់អង្គការ, ~~ការបិទផ្សព្វផ្សាយនៅការិយាល័យការិយាល័យកណ្តាល, ការិយាល័យសាខាក្នុងខេត្តដែលមានគម្រោង~~ ឬការផ្សព្វផ្សាយផ្សេងៗទៀត ។

## ទំហំការងារដេញថ្លៃ

- អង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ តទៅហៅថាភាគីប្រគល់ការងារម៉ៅការ អញ្ជើញក្រុមហ៊ុន ឬឯកត្តបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចចូលរួមដេញថ្លៃសម្រាប់សាងសង់ដូចបានបញ្ជាក់ក្នុងឯកសារដេញថ្លៃ ។
- ទីតាំងសាងសង់រួមមាន៖

| ល.រ | ឈ្មោះសាលា | ទំហំសាលា | អាសយដ្ឋាន |
|---|---|---|---|
| ១ | សាលាបបមសិក្សាភ្នាក់រលឹក | ១ខ្នង ៥បន្ទប់ និងជួសជុលបន្ទប់ទឹក២ | ខេត្តព្រះវិហារ |
| ២ | សាលាបបមសិក្សាកោះទន្សាយសែនជ័យ | ១ខ្នង ៥បន្ទប់ | ខេត្តស្ទឹងត្រែង |

- ចំពោះក្រុមហ៊ុនទទួលបានជោគជ័យ និងត្រូវបំពេញការងារឲ្យបានសព្វគ្រប់ក្នុងរយៈពេល **២១០ ប្រតិទិនថ្ងៃ និងធានា និងថែទាំក្នុងរយៈពេល១២ខែ ។**

## លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ៖

អង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ គឺអញ្ជើញជាចំហចំពោះអ្នកដេញថ្លៃ ដែលចាប់អារម្មណ៍ និងស្របច្បាប់ទាំងអស់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចខាងក្រោម៖

- ករណីជាក្រុមហ៊ុនត្រូវមានវិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ ក្រសួងពាណិជ្ជកម្ម ឬជាមួយក្រសួងពាក់ពន្ធ័ មានច្បាប់ចតសម្លងប័ណ្ណប៉ាតង់សម្រាប់ឆ្នាំ២០២៥ ឬ២០២៦ មានច្បាប់ចតចម្លងអាករលើតម្លៃបន្ថែម (VAT) ដែលមានសុពលភាព ។
- ករណីជាឯកត្តបុគ្គល ត្រូវមានអាសយដ្ឋានច្បាស់លាស់ ។
- ត្រូវមានបទពិសោធន៍យ៉ាងតិច១ឆ្នាំក្នុងការសាងសង់សាលា ដែលមានលក្ខណៈដូច ឬប្រហាក់ប្រហែលគម្រោងរបស់អង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាដែលបានធ្វើនោះ ។
- **ក្រុមហ៊ុន ឬឯកត្តបុគ្គល ដែលមិនមានប្រវត្តិសង់គម្រោងអង្គការអង្គការមូលនិធិ អេស៊ីលីដា-ចារឌីន សម្រាប់ការអប់រំ ឬគម្រោងផ្សេងទៀតមិនទទួលបានជោគជ័យ ដោយអង្គការផ្តាច់កិច្ចសន្យា ឬពេលសាងសង់មានពន្យាពេលច្រើនលើក ឬបោះបង់បន្ទាប់ពីជាប់គម្រោង ... ។**
- មិនមែនជាបុគ្គលិក ឬអ្នកពាក់ព័ន្ធ ឬនៅបម្រើការងារជាមួយអង្គការមូលនិធិ អេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ ។
- ជាក្រុមហ៊ុន ឬបុគ្គលដែលមិនមានប្រវត្តិស៊ីសំណូក និងលួចបន្លំ ។
- មានអ្នកគ្រប់គ្រងការដ្ឋាន អ្នកបច្ចេកទេស និងកម្មករ ដែលមានបទពិសោធន៍ ស្របតាមកិច្ចសន្យា ។
- មានទុនបង្វិល ក្នុងការគ្រប់គ្រង និងសាងសង់គម្រោង (យ៉ាងហោចណាស់ក្នុងដំណាក់កាលដំបូង) ។
- មានសម្ភារ និងឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់ ។

## ការបំពេញតម្លៃ

អ្នកដេញថ្លៃត្រូវតែប្រកដថាតម្លៃដែលខ្លួនបំពេញក្នុងបញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម ជាតម្លៃដែលសិក្សាច្បាស់លាស់ ពីការត្រួតពិនិត្យការដ្ឋានជាក់ស្តែង គោរពលក្ខខណ្ឌទូទៅនៃកិច្ចសន្យា បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់ គំនូសប្លង់ និងបញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម (BoQ) ដើម្បីសាងសង់បញ្ចប់មួយគម្រោងៗ ដោយមិនមានខ្វះខាតអ្វីទាំងអស់ ។ ករណីមានខ្វះខាត កែប្រែ ស្នាមលុប ឬខុសរូបមន្តក្នុងការគិតតម្លៃ អង្គការមិនទទួលខុសត្រូវឡើយ ។ រាល់ចំណាយ

ទាំងអស់ក្នុងការដាក់ដេញថ្លៃជាចំណាយរបស់អ្នកដេញថ្លៃ រួមទាំងត្រួតពិនិត្យការដ្ឋានជាក់ស្តែង ការរៀបចំឯកសារ និងចំណាយផ្សេងៗ ។

សម្គាល់៖ ករណីក្រុមហ៊ុនដែលមាន VAT 10% សូមបំពេញក្នុងបញ្ជី VAT 10 % ។ ចំពោះឯកត្តបុគ្គល ត្រូវបំពេញក្នុងបញ្ជី WHT 15% ។ ការបំពេញតម្លៃនេះ អាចបំពេញជាតម្លៃសរុបជាដំណាក់កាលៗ បាន ព្រោះក្នុងតារាងលម្អិតមិនមានរៀបរាប់បរិមាណទេ(អ្នកដេញថ្លៃត្រូវសិក្សាតម្លៃដោយយោងតាមប្លង់, លក្ខណបច្ចេកទេស, និងចុះត្រួតពិនិត្យការដ្ឋានដោយផ្ទាល់) ។

### ឯកសារដេញថ្លៃសំខាន់ៗ ៖

ក្រោយពីអាន បានចុះត្រួតពិនិត្យទីតាំងផ្ទាល់ និងបំពេញលក្ខខណ្ឌតម្រូវរួចមក អ្នកដេញថ្លៃបំពេញ ចុះហត្ថលេខា រួចដាក់ក្នុងកញ្ចប់តែមួយ បិទឲ្យជិត និងបោះត្រារបស់ក្រុមហ៊ុន ឬចុះហត្ថលេខានៅត្រង់មាត់ស្រោមសំបុត្រឲ្យបានត្រឹមត្រូវមុនផ្ញើមកយើងខ្ញុំ ។ ឯកសារទាំងអស់មានសារសំខាន់ណាស់សម្រាប់ការវាយតម្លៃស្វែងរកអ្នកទទួលម៉ៅការសាងសង់គម្រោងរបស់អង្គការ ។ សម្រាប់អ្នកដែលជាប់ក្នុងការដេញថ្លៃ អង្គការនឹងយកឯកសារទាំងអស់របស់អ្នកជាប់ធ្វើជាឧបសម្ព័ន្ធនៃកិច្ចសន្យា ។ កំហុសដែលមិនបានបំពេញតាមសំណើ នៃការដេញថ្លៃជាកំហុសផ្ទាល់របស់អ្នកដេញថ្លៃ និងអ្នកដេញថ្លៃត្រូវទទួលខុសត្រូវដោយផ្ទាល់ ។ ឯកសារទាំងនោះរួមមាន៖

1. សំណើសុំចូលរួមដេញថ្លៃ
2. សេចក្តីប្រកាសក្រមសីលធម៌វិជ្ជាជីវៈ
3. ~~ការណែនាំសម្រាប់អ្នកចូលរួមដេញថ្លៃ~~
4. ~~លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ~~
5. ~~លក្ខខណ្ឌទូទៅនៃកិច្ចសន្យា~~
6. ~~ឧបសម្ព័ន្ធ(១) បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់~~
7. ~~ឧបសម្ព័ន្ធ(២) គំនូសប្លង់~~
8. ឧបសម្ព័ន្ធ(៣) បញ្ជីវាយចំណាយលើសម្ភារ និងពលកម្ម (BoQ) និងបញ្ជីទូទាត់ចំណាយតាមដំណាក់កាល
9. ឧបសម្ព័ន្ធ(៤) ទម្រង់ប្រកាសលក្ខខណ្ឌ នៃការដេញថ្លៃ

សម្គាល់៖ អង្គការរក្សាសិទ្ធក្នុងការកែប្រែឯកសារ ព័ត៌មាន លក្ខណៈលម្អិតបច្ចេកទេស ប្លង់ និងឯកសារផ្សេងតាមករណីជាក់ស្តែង គ្រប់ពេល ក្នុងកំឡុងពេលដេញថ្លៃ ការវាយតម្លៃ និងចុះកិច្ចសន្យា តាមរយៈការជូនដំណឹងផ្ទាល់ទៅអ្នកដេញថ្លៃ ហើយឯកសារទាំងនោះមានតម្លៃសម្រាប់បញ្ចូលទៅក្នុងកិច្ចសន្យាផងដែរ ។

### ការរៀបចំឯកសារដេញថ្លៃ ៖

- ឯកសារទាំងអស់អាចប្រើជាភាសាខ្មែរ ឬអង់គ្លេស ។

- អ្នកដេញថ្លៃត្រូវត្រួតពិនិត្យបញ្ជីចំណាយលើសម្ភារ និងពលកម្ម (BoQ) ឲ្យបានច្បាស់លាស់ ដោយគិតបញ្ចូលការងារទាំងអស់ក្នុងគម្រោងនីមួយៗ ជាកញ្ចប់មួយបញ្ចប់គម្រោង ។ តម្លៃសរុបក្នុងមួយគម្រោង អ្នកដេញថ្លៃត្រូវគិតគ្រប់ចំណុចទាំងអស់តាមទំហំការងារ ដែលទៅត្រួតពិនិត្យនៅការដ្ឋានជាក់ស្តែង គោរពលក្ខខណ្ឌទូទៅ នៃកិច្ចសន្យា បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់ គំនូសប្លង់ និងបញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម (BoQ) និងព័ត៌មានផ្សេងៗទៀតដែលបានរៀបរាប់ក្នុងឯកសារនៃការដេញថ្លៃនេះ ។
- ឯកសារដេញថ្លៃទាំងអស់ត្រូវចុះហត្ថលេខា និងប្រើត្រាសម្រាប់ក្រុមហ៊ុន ចុះហត្ថលេខា និងផ្តិតមេដៃសម្រាប់ឯកត្តបុគ្គល ។
- សម្រាប់ក្រុមហ៊ុន ករណីមានអ្នកចុះហត្ថលេខជំនួស ត្រូវមានលិខិតផ្ទេរសិទ្ធភ្ជាប់មកជាមួយ ។
- អ្នកដេញថ្លៃត្រូវរៀបចំឯកសារដេញថ្លៃជា២ច្បាប់ដើម ក្នុងស្រោមសំបុត្របិទជិតដោយមានត្រា ឬចុះហត្ថលេខានៅមាត់ស្រោមសំបុត្របិទជិតនោះ ។
- អ្នកដេញថ្លៃផ្ញើឯកសារដេញថ្លៃមកអង្គការតាមការកំណត់របស់អង្គការដូចបានកំណត់ក្នុងលិខិតអញ្ជើញចូលរួមដេញថ្លៃ ។

## ដំណើរការបើក និងការវាយតម្លៃឯកសារដេញថ្លៃ

- អង្គការនឹងបើក វាយតម្លៃការដេញថ្លៃ ដោយសម្ងាត់ពីគណៈកម្មការគ្រប់គ្រងគម្រោងរបស់អង្គការផ្ទាល់ (មិនមានវត្តមានតំណាងក្រុមហ៊ុន ឬអ្នកដេញថ្លៃចូលរួមទេ) ។
- ក្រោយពីវាយតម្លៃ និងរកឃើញអ្នកជាប់ក្នុងជម្រើស (Short List) ហើយ គណៈកម្មការ នឹងចរចាតម្លៃជាមួយអ្នកជាប់ជម្រើសតាមលំដាប់ពីទីមួយមក រហូតទទួលបានអ្នកជាប់ការដេញថ្លៃជាស្វ័យប្រវត្តិ (ទាំងបច្ចេកទេស និងតម្លៃក្រោយពីការចរចា) ។ គណៈកម្មការ នឹងរៀបចំលិខិតដាក់ជូននាយកប្រតិបត្តិអង្គការ ដើម្បីសម្រេច និងចុះកិច្ចសន្យា ។
- ព័ត៌មានទាំងអស់នៃដំណើរការនៃការបើក និងការវាយតម្លៃនៃការដេញថ្លៃមិនអាចផ្តល់ជូនអ្នកចូលរួមដេញថ្លៃ ឬប្រកាសជាសាធារណៈទេ ។
- រាល់ឯកសាររបស់អ្នកចូលរួមដេញថ្លៃដែលមិនត្រូវបានជ្រើសរើស គឺមិនត្រូវបានប្រគល់ជូនវិញទេ ។

## លក្ខណៈសម្បត្តិរបស់អ្នកចូលរួមដេញថ្លៃ

អ្នកដេញថ្លៃដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងប្រសើជាងគេលំដាប់ទីមួយ និងត្រូវបានជ្រើសរើសជាអ្នកម៉ៅការសម្រាប់សាងសង់គម្រោងរបស់អង្គការ ។ ខាងក្រោមជាព័ត៌មានដែលអ្នកដេញថ្លៃត្រូវបំពេញសម្រាប់បង្ហាញពីលក្ខណៈសម្បត្តិរបស់ខ្លួន៖

## ព័ត៌មានទូទៅ៖

ឈ្មោះក្រុមហ៊ុន ឬឯកត្តបុគ្គល៖.......................................................................

បញ្ជីពាណិជ្ជកម្មលេខ៖..........................................................................

ទីកន្លែងចុះបញ្ជី៖....................................................

អាសយដ្ឋានក្រុមហ៊ុន ឬឯកត្តបុគ្គល៖..............................................

ឈ្មោះអ្នកតំណាងជាផ្លូវការ ឬឯកត្តបុគ្គល៖...................................................

អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖...............................................................

## វិញ្ញាបនប័ត្រដែលត្រូវភ្ជាប់មកជាមួយ

វិញ្ញាបនប័ត្រថតចំលងភ្ជាប់មកជាមួយ៖

1. ច្បាប់ថតចំលង វិញ្ញាបនប័ត្រចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម ឬក្រសួងពាក់ព័ន្ធ
2. ....................................................................................................................................
3. ....................................................................................................................................
4. ....................................................................................................................................

## ព័ត៌មានហិរញ្ញវត្ថុ

ចំណូលថវិកាសរុបប្រចាំឆ្នាំ ២០២៣៖.................

ចំណូលថវិកាសរុបប្រចាំឆ្នាំ ២០២៤៖.................

ចំណូលថវិកាសរុបប្រចាំឆ្នាំ ២០២៥ ឬ ២០២៦៖.................

ភ្ជាប់មកជាមួយនូវរបាយការហិរញ្ញវត្ថុ ឬរបាយការណ៍ធនាគារ ដែលអាចទុកចិត្តបាន ។

## បទពិសោធន៍របស់ក្រុមហ៊ុន

សូមរៀបរាប់បទពិសោធន៍ការងារដែលមានលក្ខណៈប្រហែលគម្រោងរបស់អង្គការឲ្យបានយ៉ាងតិច ៣ ឆ្នាំចុងក្រោយដោយបញ្ជាក់ឈ្មោះគម្រោង ទីកន្លែង ម្ចាស់គម្រោង តម្លៃគម្រោង និងមានឯកសារជាសំអាងផង៖

1. ...................................................................................................................................
2. ....................................................................................................................................
3. ....................................................................................................................................

4. ..........................................................................................................................

5. ..........................................................................................................................

6. ..........................................................................................................................

7. ..........................................................................................................................

8. ..........................................................................................................................

## គ្រឿងចក្ររបស់ក្រុមហ៊ុន

សូមរៀបរាប់គ្រឿងចក្រសម្រាប់ប្រើប្រាស់ក្នុងគម្រោងដែលអ្នកដេញថ្លៃមានដូចខាងក្រោម (ភ្ជាប់មកជាមួយតារាងគ្រឿងចក្របើមាន) ៖

1. ..........................................................................................................................

2. ..........................................................................................................................

3. ..........................................................................................................................

4. ..........................................................................................................................

5. ..........................................................................................................................

## រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ឬឯកត្តបុគ្គល

សូមរៀបរាប់រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុន ឬឯកត្តបុគ្គល ដែលមាននាទីសម្រាប់គ្រប់គ្រងគម្រោងដោយបញ្ជាក់ពីឈ្មោះ តួនាទី សញ្ញាប័ត្រ បទពិសោធ ដោយភ្ជាប់មកជាមួយប្រវត្តិរូបសង្ខេបផង ៖

1. ..........................................................................................................................

2. ..........................................................................................................................

3. ..........................................................................................................................

4. ..........................................................................................................................

5. ..........................................................................................................................

## តារាងពេលវេលា

សូមបញ្ជាក់ថាគម្រោងសាងសង់សាលាបឋម**សិក្សាភ្នាក់រលឹក(ព្រះវិហារ)** និងបឋម**សិក្សាកោះទន្សាយសែនជ័យ(រតនៈគិរី)** ត្រូវប្រើរយៈពេល ២១០ ថ្ងៃប្រតិទិន (ភ្ជាប់មកជាមួយតារាងពេលវេលាមួយគម្រោងៗ) ។

ថ្ងៃ......... ខែ............ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

.................... ថ្ងៃទី........ ខែ......... ឆ្នាំ២០២៦

ហត្ថលេខា ត្រា ឬស្នាមមេដៃ និងឈ្មោះ

តួនាទី៖...................

## លក្ខខណ្ឌទូទៅនៃកិច្ចសន្យា

អ្នកដេញថ្លៃ ឬអ្នកម៉ៅការត្រូវយល់ព្រមតាមលក្ខខណ្ឌដូចខាងក្រោមៈ

**រយៈពេល**

- អ្នកម៉ៅការត្រូវបញ្ចប់ការសាងសង់ក្នុងរយៈពេល ២១០ ថ្ងៃប្រតិទិន និងធានា និងថែទាំក្នុងរយៈពេល១២ខែ ។
- អ្នកដេញថ្លៃយល់ព្រម**ជួសជុលកែលម្អនូវចំណុចខ្វះខាត** ឬបញ្ហានានា ឲ្យចប់សព្វគ្រប់ និងអាចទទួលយកបាន **មិនលើសរយៈពេល ០៤ សប្តាហ៍** ។

**ការបង់ប្រាក់**

- ព្រមព្រៀងទូទាត់ប្រាក់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានវិក្កយបត្រ បង់ប្រាក់ច្បាប់ដើមត្រឹមត្រូវ ដោយមានភ្ជាប់ជាមួយនូវរបាយការណ៍បញ្ចប់ការងារសម្រាប់ការងារមួយៗ ដែលមានការឯកភាពពីអ្នកបច្ចេកទេស ។
- រាល់ការទូទាត់ប្រាក់ ត្រូវធ្វើឡើងដោយ មួយដំណាក់កាលម្តងៗ ឬច្រើនដំណាក់កាលម្តងតាមករណីជាក់ស្តែងដែលសម្រេចការងារបាន ហើយផ្ទេរចូលក្នុងគណនី ដែលមាននៅធនាគារ អេស៊ីលីដា ភីអិលស៊ី តាមរយៈគណនីៈ
  លេខគណនី : ..........................
  ឈ្មោះគណនី : **..........................**

**ការធានា និងការទទួលខុសត្រូវ**

- ធានាថាសំណង់ដែលបានសាងសង់ ត្រូវបានសាងសង់តាមជំនាញ និងបច្ចេកទេសស្តង់ដារ ។ ក្នុងករណីមានស្នាមប្រេះ ឬបាក់ស្រុតដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ឬខូចខាតដល់ទ្រព្យសម្បត្តិរបស់អង្គការ ឬតតិយជន ឬគ្រូ ឬសិស្ស ដោយសារមូលហេតុ នៃការសាងសង់ខុសបច្ចេកទេស កេងសម្ភារ គ្រឿងសំណង់ដោយមិនត្រូវបច្ចេកទេស ឬដោយសារតែកំហុសផ្សេងៗ ដែលបណ្តាលមកពីអ្នកដេញថ្លៃនោះ ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ និងការខូចខាតនោះ ។
- ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់ការខូចខាត និងគ្រោះថ្នាក់ផ្សេងៗ ដែលកើតឡើងលើជាង ឬកម្មកររបស់ខ្លួន និងតតិយជន ឬអង្គការ ឬគ្រូ ឬសិស្ស ក្នុងអំឡុងពេលដំណើរការបំពេញការងារ ។
- ធានាថាបានបំពេញកាតព្វកិច្ចបង់ប្រាក់ថ្លៃឈ្នួល ឬទូទាត់ប្រាក់ថ្លៃឈ្នួលជូនកម្មករ/អ្នកផ្គត់ផ្គង់របស់ខ្លួន ក្នុងករណីដែលខ្លួនមិនបានអនុវត្តតាមការអះអាងខាងលើ ដែលបណ្តាលឲ្យប៉ះពាល់រាំងស្ទះដល់ការបំពេញការងាររបស់ខ្លួន ឬធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អង្គការនោះ អង្គការមានសិទ្ធិបញ្ចប់កិច្ចសន្យាដោយឯកតោភាគី ដោយអ្នកដេញថ្លៃ ត្រូវទទួលខុសត្រូវបង់សំណងជំងឺចិត្តចំនួន១០% (ដប់ភាគរយ) នៃតម្លៃសរុបក្នុងកិច្ចសន្យាបន្ថែមលើការពិន័យ ផ្សេងៗ

ទៀត ហើយត្រូវបង្វែរប្រាក់ឈ្នួល ដែលអង្គការ បានបង់ត្រលប់ជូនអង្គការវិញនូវការងារដែលបាន មិនបានបំពេញ ។

- ត្រូវមានឧបករណ៍ ឬសម្ភារការពារសុវត្ថិភាពកម្មករ ឬជាងរបស់ខ្លួន និងធានាបាននូវរាល់ការសាងសង់របស់ខ្លួនឲ្យមានសុវត្ថិភាព មិនមានការរំខាន ឬប៉ះពាល់ដល់ការសិក្សារបស់សិស្សអង្គការ និង/ឬតតិយជនឡើយ ។
- ត្រូវទទួលខុសត្រូវក្នុងការរៀបចំប្រព័ន្ធអគ្គិសនី និងទឹក សម្រាប់ដំណើរការសាងសង់ និងធានាថាមិនឲ្យរាំងស្ទះដល់ការងារ ដោយសារមិនមានប្រព័ន្ធទឹក និងអគ្គិសនីប្រើប្រាស់គ្រប់គ្រាន់ឡើយ ។ ជាអ្នកទទួលខុសត្រូវចំណាយលើការប្រើប្រាស់ប្រព័ន្ធអគ្គិសនី ទឹក ថ្លៃឧបករណ៍-សម្ភារផ្សេងៗ ដើម្បីគ្រាំទ្រការសាងសង់សាលា ។ ករណីមានការផ្តាច់ចរន្តអគ្គិសនី ទឹក ឬគ្មានឧបករណ៍-សម្ភារផ្សេងៗ ដែលបណ្តាលមកពីអ្នកដេញថ្លៃ នោះអ្នកដេញថ្លៃ ត្រូវទទួលខុសត្រូវលើការចំណាយទាំងស្រុង ។
- អ្នកម៉ៅការ មិនត្រូវយកសម្ភារ ឬថវិការបស់គម្រោងអង្គការទៅបង្វិលខុសគោលដៅ ហើយធ្វើឲ្យយឺត ឬពន្យាពេលការសាងសង់ ។ ត្រូវចំណាយឲ្យទៅឲ្យអ្នកផ្គត់ផ្គង់ បុគ្គលិក ជាង ឬកម្មករឲ្យបានត្រឹមត្រូវ និងគ្រប់ថ្លៃនៃសម្ភារ ឧបករណ៍ ឬពលកម្ម ក្នុងកំឡុងពេលអនុវត្តការងារគម្រោងរបស់អង្គការ ។ អង្គការមិនទទួលខុសត្រូវរាល់ការទាក់ទិន នឹងការចំពាក់ថ្លៃសម្ភារ ឧបករណ៍ ឬកម្លាំងពលកម្មនោះទេ ហើយករណីនេះប្រសិនបើអង្គការរកឃើញថាក្រុមហ៊ុន ឬឯកត្តបុគ្គលបានប្រព្រឹត្តនូវអ្វីដែលបានរៀបរាប់ខាងលើ អង្គការរក្សាសិទ្ធក្នុងការផ្តាច់កិច្ចសន្យា ដោយឯកតោភាគី ហើយអ្នកម៉ៅការត្រូវសង់ទៅអ្នកផ្គត់ផ្គង់ ឬថ្លៃពលកម្មនោះតាមភាពជាក់ស្តែង ទទួលខុសត្រូវចំពោះមុខច្បាប់ និងពិន័យចំនួន ១០% នៃតម្លៃគម្រោងទាំងអស់មកអង្គការ ។

**លក្ខខណ្ឌផ្សេងៗ**

- ករណីមិនបានបំពេញការងារឲ្យរួចរាល់ត្រឹមត្រូវក្នុងពេលកំណត់សម្រាប់សាងសង់ កែចំណុចខ្វះខាត ការងារក្នុងការធានា ត្រូវទូទាត់សងជំងឺចិត្ត និងការខូចខាតស្មើនឹង 0,៥% (សូន្យក្បៀសប្រាំភាគរយ) នៃតម្លៃសរុបក្នុងកិច្ចសន្យាក្នុង១ថ្ងៃៗនៃថ្ងៃប្រតិទិន ដោយការពិន័យទាំងស្រុងមិនឲ្យលើស ១០% (ដប់ភាគរយ) នៃតម្លៃសរុបក្នុងកិច្ចសន្យានេះ ។
- នៅតែមិនទាន់បានសម្រេចការងារខាងលើក្នុងរយៈពេលលើសពី០២(ពីរ)សប្តាហ៍បន្ទាប់ពីរយៈពេលកំណត់ អង្គការអាចបញ្ចប់កិច្ចសន្យាបាន ហើយអ្នកម៉ៅការត្រូវសងត្រឡប់មកវិញនូវចំនួនទឹកប្រាក់ដែល អង្គការបានបង់ នូវការងារដែលអ្នកម៉ៅការមិនបានបំពេញ និងរួមទាំងប្រាក់សំណងជំងឺចិត្តចំនួន ១០%(ដប់ភាគរយ) នៃតម្លៃសរុបក្នុងកិច្ចសន្យាមកឲ្យអង្គការ ។
- ករណីមានការពិន័យអ្នកម៉ៅការ យល់ព្រមពន្យារពេលទូទាត់ប្រាក់ ក្នុងដំណាក់កាលជាបណ្តោះអាសន្នដោយរង់ចាំការដោះស្រាយពិន័យចប់រួចរាល់សិន ទើបធ្វើការទូទាត់ដោយកាត់

កងក្នុងវិក្កយបត្រ ។ ករណីមិនមានវិក្កយបត្រ ឬតម្លៃឧបករណ៍ផ្សេងទៀត នៅសល់ត្រូវកាត់កង អ្នកម៉ៅការ ត្រូវទូទាត់ជូន អង្គការ ក្នុងរយៈពេល០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពី អ្នកម៉ៅការ ទទួលបានវិក្កយបត្រច្បាប់ដើមពី អង្គការ ។

- ត្រូវធានាថាបានអនុវត្តត្រឹមត្រូវស្របតាមបញ្ញត្តិច្បាប់ (ច្បាប់ស្តីពីបរិស្ថាន ច្បាប់ស្តីពីការងារ...) ប្រកាស ឬបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងៗដែលមានជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ករណីអ្នកម៉ៅការ បានប្រព្រឹត្តប្រាសចាកពីបញ្ញត្តិច្បាប់ ដែលបណ្តាលឲ្យមានផលប៉ះពាល់ ផ្សេងៗ ដល់អង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ អង្គការមានសិទ្ធិបញ្ចប់កិច្ចសន្យានេះ បានភ្លាមៗដោយឥតលក្ខខណ្ឌ ហើយអ្នកម៉ៅការដែលបំពានកិច្ចសន្យាត្រូវទទួលខុសត្រូវ សំណងដែលកើតមានបណ្តាលមកពីការបំពាននេះ ។

## ការបញ្ចប់កិច្ចសន្យា

- ករណីចាំបាច់ (ដែលមិនមែនបណ្តាលមកពីកំហុសរបស់ភាគីណាមួយ) ភាគីទាំងពីរអាចស្នើសុំ បញ្ចប់កិច្ចសន្យានេះទាំងមូល ឬដោយផ្នែកមុនកាលបរិច្ឆេទកំណត់បាន ដោយគោរពតាមការ ជូនដំណឹងរយៈពេល ២០(ម្ភៃ)ថ្ងៃនៃថ្ងៃប្រតិទិនមុនថ្ងៃ ដែលភាគីមានបំណងបញ្ចប់ដោយមាន ការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរ ។ ករណីមិនបានជូនដំណឹងដូចខាងលើ ភាគីដែលសុំ បញ្ចប់កិច្ចសន្យានឹងត្រូវពិន័យចំនួន ១០% (ដប់ភាគរយ)នៃតម្លៃសរុបក្នុងកិច្ចសន្យា ហើយភាគី ទាំងពីរធ្វើការទូទាត់ការបង់ប្រាក់ទៅតាមការងារដែលបានបំពេញជាក់ស្តែង ។
- ករណីភាគីណាមួយមិនបានអនុវត្តតាមលក្ខខណ្ឌណាមួយនៃកិច្ចសន្យានេះទេ ភាគីម្ខាងទៀត មានសិទ្ធិបញ្ចប់កិច្ចសន្យាដោយឯកតោភាគី ដោយមិនចាំបាច់គោរពតាមការជូនដំណឹងជាមុន ឡើយ ហើយភាគីដែលរំលោភលើការអនុវត្ត នៃលក្ខខណ្ឌនោះនឹងត្រូវបានពិន័យជាទឹកប្រាក់ ស្មើនឹងចំនួន ១០% (ដប់ភាគរយ) នៃតម្លៃសរុបក្នុងកិច្ចសន្យា ឲ្យទៅភាគីម្ខាងទៀត ។
- ករណីភាគីណាមួយបានរំលោភបំពានលើលក្ខខណ្ឌណាមួយនៃកិច្ចសន្យា/ច្បាប់ពាក់ព័ន្ធផ្សេងៗ ឬអនុវត្តដោយបំពានដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ ឬកេរ្តិ៍ឈ្មោះរបស់ភាគីម្ខាងទៀត នោះភាគីដែលរងការខូចខាតមានសិទ្ធិបញ្ចប់កិច្ចសន្យានេះ និងកិច្ចសន្យាផ្សេងៗទៀតដែលមាន រវាងគ្នា ដោយឯកតោភាគីបានភ្លាមៗដោយមិនចាំបាច់គោរពលក្ខខណ្ឌ នៃការជូនដំណឹងទេ ។ ហើយភាគីដែលបំពាន ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងសំណងផ្សេងៗ បណ្តាលមកពីការ បំពាននេះ ។
- ភាគីទាំងពីរនឹងមិនជាប់កាតព្វកិច្ចណាមួយដែលមានចែងក្នុងកិច្ចសន្យានេះឡើយក្នុងករណី ប្រធានសក្តិដូចជា សង្គ្រាម បដិវត្តន៍ គ្រោះធម្មជាតិ ខ្យល់ព្យុះ ទឹកជំនន់ អគ្គិភ័យ រន្ទះ និងរញ្ជួយ ដី ...ល...។

- រាល់ការបញ្ចប់កិច្ចសន្យាដែលកើតឡើងដោយសារកំហុសរបស់ អ្នកម៉ៅការនោះ អ្នកម៉ៅការត្រូវសងត្រលប់មកវិញនូវរាល់ប្រាក់ដែល អង្គការបានបង់មក អង្គការវិញចំពោះការងារដែលអ្នកម៉ៅការមិនបានបំពេញដូចមានចែងក្នុងកិច្ចសន្យានេះ។
- រាល់កំហុសឆ្គងណាមួយដែលកើតឡើងដោយចេតនា ឬ អចេតនា ដោយភាគីណាមួយ ភាគីម្ខាងទៀតត្រូវជូនដំណឹងជាលើកទី១ ទៅភាគីដែលមានកំហុសដោយមធ្យោបាយសមស្របណាមួយក៏បាន។ ប្រសិន បើភាគីដែលមានកំហុសមិនបានធ្វើការកែប្រែទៅតាមការណែនាំទេនោះភាគីម្ខាងទៀតមានសិទ្ធិជូនដំណឹងជាលើកទី២ជាលាយលក្ខណ៍អក្សរ និង មានសិទ្ធិបញ្ចប់កិច្ចសន្យាជាឯកតោភាគីប្រសិនបើភាគី ដែលមានកំហុសមិនបានធ្វើការកែប្រែកំហុស បន្ទាប់ពីទទួលបានការជូនដំណឹងជាលើកទីពីរក្នុងរយៈពេល ០៧(ប្រាំពីរ)ថ្ងៃ ហើយភាគីដែលមានកំហុសត្រូវធ្វើការសងត្រលប់មកវិញនូវប្រាក់ដែលបានទូទាត់រួចទៅភាគីម្ខាងទៀត។
- អ្នកម៉ៅការត្រូវធានាថាក្នុងអំឡុងពេលអនុវត្តការងារតាមកិច្ចសន្យា ឬកិច្ចសន្យាត្រូវបានបញ្ចប់ករណីមានបុគ្គលណាម្នាក់ អះអាងថាពាក់ព័ន្ធជាមួយនឹងអ្នកម៉ៅការមករំខានដោយរូបភាពណាមួយនៅទីតាំងសាលា ឬទីតាំងណាមួយរបស់អង្គការដោយធ្វើឲ្យប៉ះពាល់ដល់ការរៀនរបស់សិស្ស ការបង្រៀនរបស់គ្រូ និងដល់ទីតាំងប្រតិបត្តិការ និង/ឬធ្វើឲ្យប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អង្គការនោះ អ្នកម៉ៅការត្រូវទទួលខុសទាំងស្រុង លើការខូចខាត ដែលកើតឡើងពីការរំខាននេះ និងត្រូវសងជំងឺចិត្ត ស្មើនឹង១០០% (មួយរយភាគរយ) នៃតម្លៃសរុបក្នុងកិច្ចសន្យា ជូនអង្គការ និងទទួលខុសត្រូវចំពោះមុខច្បាប់ ដោយគ្មានលក្ខខណ្ឌ ។

**ការអនុវត្តកិច្ចសន្យា**

- កិច្ចសន្យានេះ ស្ថិតនៅក្រោមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ករណីមានវិវាទកើតឡើងទាក់ទិននឹងការប្រតិបត្តិនៃកិច្ចសន្យានេះវិវាទនឹងត្រូវដោះស្រាយដោយការចរចាគ្នាដោយសន្តិវិធី ។ ករណីវិវាទនៅតែមិនអាចដោះស្រាយបាន សំណុំរឿងវិវាទអាចត្រូវបានដោះស្រាយតាមរយៈសន្ទានកម្ម ឬការផ្សះផ្សា ឬអាចត្រូវបានដោះស្រាយតាមប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។
- កិច្ចសន្យានេះ ត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងគ្នាដោយពិតប្រាកដ និងដោយសេរីរវាងភាគីទាំងសងខាងលើរាល់លក្ខខណ្ឌដែលបានចែង។ រាល់ការកែប្រែ ឬវិសោធនកម្មលើផ្នែកណាមួយនៃកិច្ចសន្យាអាចប្រព្រឹត្តទៅបានដោយមានការព្រមព្រៀងពីភាគីទាំងពីរ។

- កិច្ចសន្យានេះ ធ្វើឡើងជា០២(ពីរ) ច្បាប់ដើម ជាភាសាខ្មែរមានតម្លៃស្មើគ្នាដោយរក្សាទុកនៅអ្នកម៉ៅការចំនួន ០១(មួយ) ច្បាប់ដើម និងអង្គការចំនួន ០១(មួយ) ច្បាប់ដើម។

ថ្ងៃ......... ខែ............ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

.................... ថ្ងៃទី........ ខែ......... ឆ្នាំ២០២៦

ហត្ថលេខា ត្រា ឬស្នាមមេដៃ និងឈ្មោះ

តួនាទី៖..................

## ឧបសម្ព័ន្ធ ០១
## បទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់
## បទដ្ឋានបច្ចេកទេស

**ការរៀបចំការដ្ឋាន**

ការដ្ឋានត្រូវតែសម្អាតឲ្យបានស្អាត់នៅទីតាំងសម្រាប់សាងសង់ ដីនៅក្នុងការដ្ឋាន ត្រូវតែយកស្មៅ ឫសឈើ ចេញឲ្យអស់ ។ ត្រូវរៀបចំកន្លែងដាក់សម្ភារសម្រាប់សង់សាលាឲ្យបានត្រឹមត្រូវដើម្បីការពារសម្ភារសំណង់ឲ្យរក្សាគុណភាពបានល្អ ។

**ការងារបេតុង៖**

បេតុងដែលយកមកប្រើ គឺត្រូវតែមានកម្រិតកម្លាំងដូចដែលបានបញ្ជាក់នៅក្នុងប្លង់ និងបទដ្ឋានបច្ចេកទេស និងលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ និងការប្រើប្រាស់ ។ ករណីពិសេស ចាំបាច់ត្រូវយកសំណាក់គម្រូក្នុងអំឡុងពេលដំណើរការសាងសង់សម្រាប់ការធ្វើតេស្ត ដើម្បីបញ្ជាក់ពីភាពរឹងមាំ ។

**ជើងតាង៖**

**ការជីកដី៖** ដីត្រូវជីកសម្រាប់ធ្វើជើងតាង គឺជីករាងចតុកោណកែង ត្រូវមានទំហំអប្បបរិមា ១,២ម*១,២ម និងមានជម្រៅរដិបរដុប១,៥៥មពីដីធម្មជាតិ ។

**ការរៀបចំបាតក្រោមជើងតាង៖** ត្រូវបង្ហាប់ដោយស្រទាប់ ថ្ម៤០មម*៦០មម ជាមួយបាយអរស្ងួត ( ស៊ីម៉ង់ត៍ ១៥០ គក និងខ្សាច់គ្រើម ១មគ) ដែលមានទំហំ១,២ម*១,២ម*០,១ម ។

**ជើងតាង៖** ត្រូវរៀបចំពុម្ព ប្រើដែក និងបេតុងឲ្យបានត្រឹមត្រូវតាមគំនូសប្លង់ ហើយមានទំហំ ១ម*១ម*០,២ម ។

**សសរសតឿ៖**

សសរតឿមានពីរប្រភេទ គឺសសរតឿមានទំហំ ០,២ម*០,២ម*១,៥ម ចំនួន ៣០ដើម និង០,២៥ម*០,២៥ម*១,៥ម ចំនួន ១០ដើមសម្រាប់ ៥បន្ទប់ និងសសរតឿមានទំហំ ០,២ម*០,២ម*១,៥ម ចំនួន ២០ដើម និង០,២៥ម*០,២៥ម*១,៥ម ចំនួន ៦ដើមសម្រាប់ ៣បន្ទប់។

**ជញ្ជាំងទប់ដី៖**

ជញ្ជាំងទប់ដីមួយជុំក្រោមកម្រាលជាន់ គឺត្រូវជីកដី ទំហំ ០,៤ម*០,៤ម*១០២ម ក្រាលដោយការបង្ហាប់ថ្ម ៤០មម*៦០មម លាយជាមួយបាយអរស្ងួត ( ស៊ីម៉ង់ត៍១៥០គក និងខ្សាច់គ្រើម ១មគ) ទំហំ ០,៤ម*០,១ម*១០២ម និងរៀបឥដ្ឋប្រហោងកម្រាស់ ០,២០ម ។

**ការបង្ហាប់ដីក្រោមកម្រាលជាន់៖**

ការបង្ហាប់ដីក្រោមកម្រាលជាន់ គឺត្រូវជ្រើសរើសយកដីដែលមានគុណភាពល្អ ឬដីខ្សាច់ ដោយចាក់ពង្រាយជាស្រទាប់មួយជាន់ៗ រួចបង្ហាប់ និងស្រោចទឹកឲ្យបានណែនល្អ មុននឹងដាក់មួយជាន់ទៀត ធ្វើដូចនេះរហូតដល់បំពេញដីបានរួចរាល់ ។

**ការងារធ្នឹមក្រោម៖**

ធ្នឹមក្រោម គឺមានទំហំ០,២ម*០,៣ម ធ្វើពីបេតុងដូចគំនូសប្លង់ ។ នៅចន្លោះពីក្តារពុម្ព ទៅដែក ត្រូវមានទ្រនាប់ទប់ ដើម្បីឲ្យដែកនៅចន្លោះកណ្តាល និងមានកម្រាស់បេតុងនៅជុំវិញដែកយ៉ាងហោចណាស់កម្រាស់ ២០មម ។ បន្ទាប់ពីចាក់បេតុងរួច ត្រូវចិញ្ចឹមទឹកឲ្យបានសើមរហូត ។ ក្តារពុម្ពត្រូវរក្សាទុកមុននឹងដោះចេញយ៉ាងហោចណាស់៧ថ្ងៃ ។

**ការងារបង្ហាប់ថ្មក្រោមកម្រាលជាន់៖**

នៅក្រោមកម្រាលជាន់ ត្រូវបង្ហាប់ ថ្ម៤*៦ លាយជាមួយបាយអរស្ងួត (ស៊ីម៉ង់ត៍១៥០គក និងខ្សាច់គ្រើម ១មគ) កម្រាស់០,១ម និងបាញ់ទឹកឲ្យជោក ។

**ជម្រាលជនពិការ ជណ្តើរ និងកន្លែងដាំផ្កា៖**

ជម្រាលជនពិការ ជណ្តើរ និងការងារកន្លែងដាំផ្កា គឺត្រូវជីកដីទំហំ ០,៣ម*០,៣ម បង្ហាប់ថ្ម៤*៦ លាយជាមួយបាយអរស្ងួត (ស៊ីម៉ង់ត៍១៥០គក និងខ្សាច់គ្រើម ១មគ) កម្រាស់០,១ម ចាក់ធ្នឹមទប់ទំហំ ០,២ម*០,២ម រៀបឥដ្ឋ២០មម សម្រាប់ និងបង្ហាប់ថ្ម៤*៦ លាយជាមួយបាយអរស្ងួត (ស៊ីម៉ង់ត៍១៥០គក និងខ្សាច់គ្រើម ១មគ) បំពេញចន្លោះជម្រាលជនពិការ និងកាំជណ្តើរ ។ ចំណែកឯបាតក្រោមកន្លែងដាំផ្ការត្រូវរក្សាឲ្យនៅដីធម្មជាតិ ឬអាចជ្រាបទឹកបាន ដើម្បីកុំឲ្យរុក្ខជាតិជាំទឹក ។ កន្លែងដាំផ្ការ ឬរុក្ខជាតិត្រូវបំពេញដីដែលអាចដាំដុះបាន ។

**ការងារសរសរ៖**

សរសរមានពីប្រភេទ គឺ០,២ម*០,២*ម*៣,៨ម និង០,២៥ម*០,២៥ម*៣,៦ម ធ្វើពីបេតុងដូចក្នុងគំនូសប្លង់ ។ មុននឹងរៀបចំពុម្ព ត្រូវសម្អាតផ្ទៃកខាងក្រោម នៃសរសរដែលត្រូវឈរ ដោយដាប់ឲ្យមានជម្រៅរដិបរដុបប្រហែល ១៥មម ។ នៅចន្លោះពីក្តារពុម្ព ទៅដែក ត្រូវមានទ្រនាប់ទប់ ដើម្បីឲ្យដែកនៅចន្លោះកណ្តាល និងមានកម្រាស់បេតុងនៅជុំវិញដែកយ៉ាងហោចណាស់កម្រាស់ ៣០មម ។ បន្ទាប់ពីចាក់បេតុងរួច ត្រូវចិញ្ចឹមទឹកឲ្យសសរបានសើមរហូត ។ ក្តារពុម្ពសសរត្រូវរក្សាទុកមុននឹងដោះចេញយ៉ាងហោចណាស់៤ថ្ងៃ ។

**ការងាររៀបឥដ្ឋជញ្ជាំង៖**

ការរៀបឥដ្ឋសម្រាប់ជញ្ជាំងមានពីប្រភេទគឺ ជញ្ជាំងឥដ្ឋ ២០ និង ឥដ្ឋ១០ ដែលត្រូវរៀបឲ្យត្រង់ និងស្មើបានល្អ ។ ឥដ្ឋដែលយកមកប្រើជាឥដ្ឋដែលមានគុណភាពល្អ ពេញខ្នាត និងឆ្អិនល្អ ។ មុននឹង

រៀបឥដ្ឋត្រូវត្រាំទឹកឲ្យជោក ពេលរៀបត្រូវប្រើប្រភេទបាយអរដែលមានកម្លាំងជាប់មាំ៧៥គក/សម២ រក្សាចន្លោះ១៥មម ភ្ជាប់ពីឥដ្ឋមួយទៅមួយទៀត ។ ការរៀបឥដ្ឋត្រូវគោរពតាមបទដ្ឋានរៀបឥដ្ឋ ។

**ឡាំងតូ៖**

គ្រប់តំណរភ្ជាប់រវាងឡាំងតូ ជាមួយសរសរ ឬធ្នឹមត្រូវដាប់ឲ្យមានជម្រៅរដេបរដុបរដេចរដុប ប្រហែល 15មម ដើម្បីបង្កើតឲ្យមានផ្ទៃសម្រាប់ការតភ្ជាប់ ។ ត្រូវមានទ្រនាប់ចន្លោះក្តាររពុម្ព និងដែក យ៉ាងតិច ២០មម និងក្តាររពុម្ពត្រូវរក្សាទុកមុននឹងដោះចេញយ៉ាងហោចណាស់៧ថ្ងៃ ។

**ការងារធ្នឹម និងសរសរសម្រាប់ដំបូល៖**

**ការងារធ្នឹមលើ៖** ធ្នឹមលើ គឺធ្វើពីបេតុងដូចគំនូសប្លង់។ រាល់តំណរភ្ជាប់ត្រូវដាប់ឲ្យមានជម្រៅរដេបរដុបយ៉ាងហោចណាស់មានជម្រៅ១៥មម ។ នៅចន្លោះពីក្តាររពុម្ពទៅដែក ត្រូវមានទ្រនាប់ទប់ដើម្បីឲ្យដែកនៅចន្លោះកណ្តាល និងមានកម្រាស់បេតុងនៅជុំវិញដែកយ៉ាងហោចណាស់កម្រាស់ ២០មម ។ បន្ទាប់ពីចាក់បេតុងរួច ត្រូវចិញ្ចឹមទឹកឲ្យបានសើមរហូត ។ ក្តាររពុម្ពត្រូវរក្សាទុកមុននឹងដោះចេញយ៉ាងហោចណាស់៧ថ្ងៃ ។

**សសរដំបូល៖** គ្រប់សសរទាំងអស់ត្រូវតែត្រង់ និងមានទំហំតាមគំនូសប្លង់ និងមានកម្រិតលម្អៀងតិចតួចបំផុតមិនឲ្យលើស+-១៥មម ។

**បង្កង់ និងដែរណែង៖**

បង្កង់ ត្រូវប្រើដែកមានទំហំ ៤០*៤០*១,៥មម ដែលមានគម្លាត៨០០មម និងដែរណែងត្រូវប្រើដែកទំហំ២៥*២៥*១,៥មម មានគម្រាត ៣២០មម ដែលលាបថ្នាំច្រែះកន្លែងផ្សារ ។

**ក្បឿង ព្រំ និងជហ្វា៖**

ក្បឿង និងព្រំដែលប្រើ គឺក្បឿង ជីបម៉ុង (Chip Mong tile) ឬឆ្លង Sample ជាក់ស្តែង

ជហ្វា ដែលត្រូវប្រើគឺ ជហ្វាសម្រាប់ដាក់សាលារៀន

**ការងារឈើ ឬដែក៖**

ករណីប្រើប្រាស់ឈើធម្មជាតិ ត្រូវប្រើប្រាស់ឈើដែលស្របច្បាប់ និងមិនធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន ឬច្បាប់ជាតិ និងអន្តរជាតិឡើយ ។ ឈើដែលយកមកប្រើត្រូវសម្ងួតឲ្យស្ងួត មុននឹងយកមកប្រើប្រាស់ ។

រាល់ការងារទ្វារបង្អួច ឬការងារផ្សេងទៀតដែលប្រើប្រាស់ឈើ អាចប្រើប្រាស់ជាដែកបាន តែត្រូវមានគុណភាពល្អ នឹងអាចទទួលយកបានដូចមានក្នុងគំនូសប្លង់ ។

**គ្រោងទ្វារបង្អួច៖** ត្រូវដំឡើងតាមទំហំ និងទម្រង់ស្របតាមគំនូសប្លង់ ដែលធ្វើពីឈើមានគុណភាពល្អ ដូចជា ដូងថែម គគីរ ធ្នង់ ឬដែកដែលមានកម្រាស់អាចទទួលយកបានជាដើម ។

**ទ្វារ៖** ត្រូវដំឡើងតាមទំហំ និងទម្រង់ស្របតាមគំនូសប្លង់ ដែលធ្វើពីឈើមានគុណភាពល្អ ដូចជា ដូងចែម គគីរ ធ្នង់ ឬដែកដែលមានកម្រាស់អាចទទួលយកបានជាដើម ។ គ្រប់ទ្វារទាំងអស់ត្រូវប្រើ ត្រចៀក គន្លឹះ ប្រដាប់ចាក់សោរ និងសោរដែលមានគុណភាពអាចទទួលយកបាន ។

**បង្អួច៖** ត្រូវដំឡើងតាមទំហំ និងទម្រង់ស្របតាមគំនូសប្លង់ ដែលធ្វើពីឈើមានគុណភាពល្អ ដូចជា ដូងចែម គគីរ ធ្នង់ ឬដែកដែលមានកម្រាស់អាចទទួលយកបានជាដើម ។ គ្រប់បង្អួចទាំងអស់ត្រូវប្រើ ត្រចៀក គន្លឹះ ដែលមានគុណភាពអាចទទួលយកបាន ។

**កម្រាលជាន់៖**

កម្រាល់ជាន់ត្រូវចងដែក ឬ Wire Mesh និងចាក់បេតុងឲ្យបានដូចគំនូសប្លង់ ពីលើការបង្ហាប់ថ្ម ៤*៦ ដែលមានកម្រាស់០,០៦ម ហើយផ្ទៃកខាងលើត្រូវខាត់ឲ្យរលោង រាបស្មើ និងមានជម្រាលមិនអាចដក់ទឹកបាន ។

**ការងារលាបថ្នាំ៖**

ការប្រើថ្នាំលើផ្ទៃដែក៖ ត្រូវខាត់រាល់ផ្ទៃដែលត្រូវលាបថ្នាំ ឲ្យមានភាពរលោង ស្អាត និងស្ងួត បន្ទាប់មកត្រូវលាបថ្នាំស្រទាប់ ដើម្បីការពារច្រេះ និងលាបថ្នាំប្រេងពណ៌ ឬប្រភេទថ្នាំ All in one យ៉ាងតិចចំនួន ២ ស្រទាប់ ។ ការលាបថ្នាំត្រូវតែលាបឲ្យរលោង ស្មើសាច់ទើបអាចទទួលយកបាន ។ ពណ៌ដែលត្រូវលាបគឺត្រូវយកតាមពណ៌ដូចមានក្នុងគំនូសប្លង់ ។

ការប្រើថ្នាំលើផ្ទៃបាយអរ៖ រាល់ផ្ទៃជញ្ជាំងទាំងអស់ដែលត្រូវលាប ត្រូវសម្អាត ស្មើ និងស្ងួតត្រឹមត្រូវ មុននឹងបៀកម្សៅបៀក ។ ម្សៅបៀកត្រូវលាយតាមសមាមាត្របច្ចេកទេស និងដោយប្រើម៉ាស៊ីនកូរឲ្យបានស្មើសាច់ ។ ការបៀកត្រូវតែបៀកឲ្យបានស្មើ និងស្អាត រួចទុកឲ្យស្ងួត ។ មុននឹងលាបថ្នាំត្រូវតែខាត់ឲ្យស្អាត និងរលោង ។ ការលាបថ្នាំត្រូវលាប មួយស្រទាប់ៗម្ដង និងរក្សាគម្លាតយ៉ាងហោចណាស់ 24 ម៉ោង ធ្វើយ៉ាងនេះរហូតទទួលបានជោគជ័យ និងអាចទទួលយកបាន (មានពណ៌ស្មើសាច់) ។

ការប្រើថ្នាំលើផ្ទៃឈើ៖ មុននឹងលាបថ្នាំ ត្រូវសម្អាតផ្ទៃដែលត្រូវលាបឲ្យបានស្អាត ស្មើ និងស្ងួត ។ ករណីមិនស្មើត្រូវប្រើថ្នាំបៀកសម្រាប់ឈើ និងខាត់ឲ្យស្មើ បន្ទាប់មកត្រូវលាបថ្នាំទ្រនាប់ ថ្នាំពណ៌ រហូតដល់ស្មើសាច់ និងអាចទទួលយកបាន ។ រាល់ពេលលាបក្នុង មួយស្រទាប់ៗ ត្រូវរក្សាគម្លាតយ៉ាងហោចណាស់ 24 ម៉ោង ។

## បទដ្ឋានក្នុងការប្រើសម្ភារសម្រាប់បេតុង និងបាយអរ

ល្បាយបេតុង៖

ការលាយបេតុងទាំងអស់ដែលប្រើប្រាស់ក្នុងការសាងសង់នេះ ត្រូវតែអនុវត្តតាមរូបមន្ត ដែលបានកំណត់ ។ រាល់ពេលលាយបេតុងត្រូវប្រើខ្នាត់ដែលមានរង្វាស់ច្បាស់លាស់ ។ ល្បាយបេតុងដែលលាយមិនត្រឹមត្រូវមិនអាចទទួលយកបានឡើយ ។

លាយបេតុង៖ ការលាយបេតុង ត្រូវប្រើម៉ាស៊ីនសម្រាប់លាយបេតុង ដើម្បីឲ្យសមាសធាតុសម្រាប់បង្កើតជាបេតុងលាយចូលគ្នាបានសព្វល្អ ។

ស៊ីម៉ង់ត៍៖ ត្រូវប្រើស៊ីម៉ងត៍ដែលមានម៉ាក **PORTLAND CEMENT** / CONCH / V Cement / Camel / KINGDOM និងមិនអនុញ្ញាតឲ្យប្រើប្រភេទស៊ីម៉ង់ត៍ផ្សេងទេ លុះត្រាណាតែមានការឯកភាពជាលក្ខណ៍អក្សរពីអ្នកបច្ចេកទេស ។ ការផ្លាស់ប្តូរប្រភេទស៊ីម៉ង់ត៍ អ្នកម៉ៅការជាអ្នកទទួលខុសត្រូវក្នុងការផ្តល់ឯកសារបច្ចេកទេសពីការប្រើប្រាស់ និងគុណភាពរបស់ស៊ីម៉ង់ត៍ ។

ខ្សាច់៖ ខ្សាច់ដែលប្រើសម្រាប់ផលិតបេតុង ជាខ្សាច់ស្អាត មានគុណភាពល្អ និងមានទំហំចន្លោះពី១មម ទៅ ៥មម ហើយមិនមានដីភក់ ដីឥដ្ឋ ឬកម្ទេចកម្ទី រុក្ខជាតិផ្សេងៗ នៅលាយឡំក្នុងនោះជាដាច់ខាត ជាពិសេស ស្បោងផ្លាស្ទិច ។

ថ្ម៖ ថ្មប្រើសម្រាប់បេតុង ជាថ្មស្អាត រឹងមាំ មានទំហំប៉ុនៗគ្នា ១០មម * ២០មម រាងជាត្រីកោណ ហើយមិនមានដីភក់ ដីឥដ្ឋ ឬកម្ទេចកម្ទី រុក្ខជាតិផ្សេងៗ នៅលាយឡំក្នុងនោះជាដាច់ខាត ជាពិសេស ស្បោងផ្លាសស្ទិច ។

ដែក៖ ដែកសរសៃ លួសចំណង ទាំងអស់ដែលប្រើក្នុងមេតុងអាមេត្រូវមានខ្នាតពេញលេញ មានគុណភាពល្អ ដែកកងមានរ៉េស៊ីស្តង់ ២៣៥ Mpa ដែកគ្រឿងបង្គុំ មានរ៉េស៊ីស្តង់ ៣៩០ Mpa មានរូបរាងថ្មី គ្មានច្រែះស៊ី ។ សរសៃដែកចាប់ពី១០មមឡើងទៅត្រូវប្រើដែកថ្នាំងអំពៅ ។

ទឹក៖ ទឹកត្រូវប្រើទឹកដែលមានគុណភាពល្អ តាមសមមាត្រនៃការលាយឲ្យបានត្រឹមត្រូវ មិនត្រូវប្រើទឹកស្រះល្អក់ កករ លាយដាក់ទឹកតិច ឬច្រើនពេក ។

របៀបលាយបេតុង៖

កម្លាំងបេតុងសម្រាប់គ្រឹះ សរសរ ធ្នឹម កម្រាលជាន់

លាយល្បាយបេតុងក្នុង ១ម៉ែត្រគូបត្រូវមានសមមាត្រដូចខាងក្រោម៖

| | |
|---|---|
| ស៊ីម៉ង់ត៍ | ៤០០គក (៨បាវ) |
| ខ្សាច់គ្រើមស្អាត | ០,៥០មគ |
| ថ្មទំហំ ១០*២០មម | ០,៨៧មគ |
| ទឹកស្អាត | ២០០ល |

ការលាយល្បាយបេតុងសម្រាប់មួយលើកៗ ក្នុង ស៊ីម៉ង់ត៍១បាវត្រូវមានសមមាត្រដូចខាងក្រោម៖

| | |
|---|---|
| ស៊ីម៉ង់ត៍ | ៥០គក (១បាវ) |
| ខ្សាច់គ្រើមស្អាត | ៤ ធុងស្តិកត្រូល |
| ថ្មទំហំ ១០*២០មម | ៦ ធុងស្តិកត្រូល |
| ទឹកស្អាត | ១,៤ ធុងស្តិកត្រូល |

របៀបលាយបាយអរ៖

បាយអរ ត្រូវលាយទៅតាមបទដ្ឋាន ស៊ីម៉ង់ត៍១ភាគ ខ្សាច់៣ភាគ (១/៣) ។

បាយអរសម្រាប់រៀបឥដ្ឋក្នុង១មគត្រូវប្រើ៖

| | |
|---|---|
| ស៊ីម៉ង់ត៍ (Portland) | ៣០០គក (៦បាវ) |
| ខ្សាច់គ្រើមស្អាត | ១ មគ |
| ទឹកស្អាត | ២២០ ល |

បាយអរសម្រាប់បូកក្នុង១មគត្រូវប្រើ៖

| | |
|---|---|
| ស៊ីម៉ង់ត៍ (Portland) | ៣០០គក (៦បាវ) |
| ខ្សាច់គ្រើមស្អាត | ១ មគ |
| ទឹកស្អាត | ២២០ ល |

បាយអរសម្រាប់រៀបឥដ្ឋ និងបូកក្នុងស៊ីម៉ង់ត៍១បាវ (ជាមួយម៉ាស៊ីនលាយ) ត្រូវប្រើ៖

| | |
|---|---|
| ស៊ីម៉ង់ត៍ (Portland) | ៥០គក (១បាវ) |
| ខ្សាច់គ្រើមស្អាត | ៨ ធុងស្តិកត្រូល |
| ទឹកស្អាត | ២ ធុងស្តិកត្រូល |

## បញ្ជីលក្ខណៈបច្ចេកទេសលម្អិតនៃសម្ភារ

ខាងក្រោមជាលក្ខណៈបច្ចេកទេសលម្អិត នៃសម្ភារសម្រាប់គម្រោងនេះ ៖

| រូបភាព | លក្ខណលម្អិតបច្ចេកទេស | |
|---|---|---|
| | ឈ្មោះផលិតផល | ស៊ីម៉ង់ត៍ **PORTLAND CEMENT** / CONCH / V Cement / Camel / KINGDOM |
| | កូដ | |
| | មុខកាត់ | |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | ក្នុងស្រុក |
| | ការប្រើប្រាស់ | បេតុង និងបាយអរ |
|  | ឈ្មោះ | ថ្ម ១០ * ២០មម |
| | កូដ | |
| | មុខកាត់ | ១គុណ២សម |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | ក្នុងស្រុក |
| | ការប្រើប្រាស់ | បេតុង |
|  | ឈ្មោះ | ថ្ម ៤០*៦០មម |
| | កូដ | |
| | មុខកាត់ | ៤*៦សម |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | ក្នុងស្រុក |
| | ការប្រើប្រាស់ | គ្រឹះ កម្រាលជាន់ |
|  | ឈ្មោះ | ខ្សាច់ គ្រើម(ទន្លេ ឬស្ទឹង) |
| | កូដ | |
| | មុខកាត់ | |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | ក្នុងស្រុក |
| | ការប្រើប្រាស់ | បេតុង បូក សាប |

| | | |
|---|---|---|
|  | ឈ្មោះផលិតផល | ដែក SD390 (Pomina, ISI, V, 7ST, MK(25), VHS... |
| | កូដ | |
| | មុខកាត់ | តាមប្លង់ |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | នាំចូល/ក្នុងស្រុក |
| | ការប្រើប្រាស់ | បេតុង |
|  | ឈ្មោះផលិតផល | ដែក កម្រាស់ ១,៥មម |
| | កូដ | |
| | មុខកាត់ | តាមប្លង់ |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | នាំចូល/ក្នុងស្រុក |
| | ការប្រើប្រាស់ | គ្រោងដំបូល |
|  | ឈ្មោះផលិតផល | ឥដ្ឋប្រហោង |
| | កូដ | |
| | មុខកាត់ | |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | ក្នុងស្រុក |
| | ការប្រើប្រាស់ | ជញ្ជាំងខណ្ឌ |
|  | ឈ្មោះផលិតផល | ថ្នាំលាប |
| | កូដ | |
| | មុខកាត់ | |
| | ពណ៌ | តាមប្លង់ |
| | គុណភាព | ល្អ |
| | ផលិតផល | |
| | ការប្រើប្រាស់ | លាបជញ្ជាំង |
| | ឈ្មោះផលិតផល | គ្រឿង Chip Mong, ឬមាន Sample ផ្ទាល់...... |
| | កូដ | |

| | | |
|---|---|---|
|  | មុខកាត់ | |
| | ពណ៌ | |
| | គុណភាព | ល្អ |
| | ផលិតផល | ក្នុងស្រុក |
| | ការប្រើប្រាស់ | ដំបូល |
|  | ឈ្មោះផលិតផល | ជហ្វា |
| | កូដ | |
| | មុខកាត់ | |
| | ពណ៌ | |
| | គុណភាព | |
| | ផលិតផល | |
| | ការប្រើប្រាស់ | ដំបូល |
|  | ឈ្មោះផលិតផល | ឥដ្ឋខ្យល់ |
| | កូដ | |
| | មុខកាត់ | |
| | ពណ៌ | |
| | គុណភាព | |
| | ផលិតផល | |
| | ការប្រើប្រាស់ | ស្លាបព្រិល |
|  | ឈ្មោះផលិតផល | អាលុយកាបូន |
| | កូដ | អាលុយកាបូន |
| | ពណ៌ | ត្រាវ |
| | កម្រាស់ | ៤មម |
| | ការប្រើប្រាស់ | ស្លាកឧបត្ថម្ភ (Signboard) |

ថ្ងៃ......... ខែ............ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

.................... ថ្ងៃទី........ ខែ......... ឆ្នាំ២០២៦

ហត្ថលេខា ត្រា ឬស្នាមមេដៃ និងឈ្មោះ

តួនាទី៖...................

**ឧបសម្ព័ន ០២**

**គំនូសប្លង់ (សូមមើលគំនូសប្លង់លម្អិតភ្ជាប់មកជាមួយ)**

Appendix-2 Drawing- **Phneak Roluek** Building (គំនូសប្លង់អគារ ៥បន្ទប់)

Appendix-2 Drawing- **Koh Tonsay Saenchey** Building (គំនូសប្លង់អគារ ៥បន្ទប់)

**ឧបសម្ព័ន ០៣**

**បញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម (BoQ) & បញ្ជីទូទាត់ចំណាយតាមដំណាក់កាល**

**(សូមមើលបញ្ជីរាយចំណាយលើសម្ភារ និងពលកម្ម លម្អិតភ្ជាប់មកជាមួយ)**

Appendix-3&4 BoQ & Milestone (**Phneak Roluek** 5 Rooms)

Appendix-3&4 BoQ & Milestone (**Koh Tonsay Saenchey** 5 Rooms)

**ឧបសម្ព័ន ០៤**

**ទម្រង់ប្រកាសលក្ខខណ្ឌនៃការដេញថ្លៃ**

# ចប់

អេ ជេ អេហ្វ
ACLEDA-JARDINES FOUNDATION